MassDEP
Commonwealth of Massachusetts
Executive Office of Energy & Environmental Affairs

# Department of Environmental Protection

One Winter Street Boston, MA 02108 • 617-292-5500

Charles D. Baker
អភិបាលរដ្ឋ

Karyn E. Polito
អនុអភិបាលរដ្ឋ

Bethany A. Card
លេខាធិការ

Martin Suuberg
ស្នងការ

## សេចក្ដីជូនដំណឹងស្ដីពីសវនាការសាធារណៈ:
## បទប្បញ្ញត្តិចំណងជើងទី 5 និងលិខិតអនុញ្ញាតទីជម្រាល

សេចក្ដីជូនដំណឹងស្ដីពីសវនាការសាធារណៈនេះគឺមានជាភាសាផ្សេងទៀត (អេស្ប៉ាញ -- វៀតណាម -- ចិន -- ហៃទីក្រេអូល -- ព័រទុយហ្គាល់ -- ខ្មែរ) នៅលើគេហទំព័ររបស់ MassDEP នៅ៖ https://www.mass.gov/service-details/massdep-public-hearings-comment-opportunities

សេចក្ដីជូនដំណឹង មានសេចក្ដីថា យោងតាម M.G.L. c. 30A ក្រសួងការពារបរិស្ថាន (MassDEP) កំពុងស្នើសុំធ្វើវិសោធនកម្មក្រមបរិស្ថានរដ្ឋ ចំណងជើងទី 5, 310 CMR 15.000 និងប្រកាសឲ្យប្រើបទប្បញ្ញត្តិថ្មី ដែលមានចំណងជើងថា បទប្បញ្ញត្តិស្ដីពីលិខិតអនុញ្ញាតទីជម្រាល នៅត្រង់ 314 CMR 21.00 ទាក់ទងទៅនឹងអំណាចរបស់ខ្លួននៅត្រង់ M.G.L. c. 21A § 13, G.L. c. 21 § 27 និងមាត្រាទី 2A នៃជំពូក 259 នៃច្បាប់ឆ្នាំ 2014។ MassDEP កំពុងស្នើសុំធ្វើវិសោធនកម្មបទប្បញ្ញត្តិចំណងជើងទី 5 ដើម្បីបង្កើនការការពារឆកសមុទ្រ និងមាត់ពាម—ជាពិសេសនៅលើឧបទ្វីប Cape Cod កោះនានា និងរដ្ឋ Massachusetts ភាគអាគ្នេយ៍—ពីការបំពុលដោយអាសូតដែលមានប្រភពចម្បងមកពីទឹកកខ្វក់។ បទប្បញ្ញត្តិដែលបានស្នើឡើងរបស់ MassDEP នៅត្រង់ 314 CMR 21.00 ចែងថាទីជម្រាលអនុញ្ញាតឲ្យមានវិធីសាស្ត្រក្នុងការគ្រប់គ្រងអាសូត និងធាតុកខ្វក់ដទៃទៀតមិនឲ្យចូលទៅក្នុងឆកសមុទ្រ និងមាត់ពាម។
វិសោធនកម្ម និងបទប្បញ្ញត្តិដែលបានស្នើឡើងគឺមាននៅលើគេហទំព័ររបស់ MassDEP នៅ៖ https://www.mass.gov/service-details/massdep-public-hearings-comment-opportunities

**<u>មតិយោបល់ និងសវនាការសាធារណៈ:</u>**

MassDEP នឹងធ្វើសវនាការសាធារណៈចំនួនបី។

**ដោយមានវត្តមានផ្ទាល់ និងពីចម្ងាយ, MassDEP, 20 Riverside Dr., Lakeville, MA ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2022 នៅម៉ោង 6:00 ល្ងាច។** ចុះឈ្មោះសម្រាប់វគ្គសវនាការពីចម្ងាយទុកជាមុននៅ៖
https://us06web.zoom.us/webinar/register/WN_oay0_6bGTjeEUzevfxm7Jg

**តែពីចម្ងាយប៉ុណ្ណោះ ថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2022 នៅម៉ោង 1:00 រសៀល។** ចុះឈ្មោះទុកជាមុននៅ៖
https://us06web.zoom.us/webinar/register/WN_BTOR_A3oSI6EZm56mYdoRw

**ដោយមានវត្តមានផ្ទាល់ និងពីចម្ងាយ Barnstable Town Hall, 367 Main St., Hyannis, MA ថ្ងៃទី 5 ខែធ្នូ ឆ្នាំ 2022 នៅម៉ោង 6:00 ល្ងាច។** ចុះឈ្មោះសម្រាប់វគ្គសវនាការពីចម្ងាយទុកជាមុននៅ៖
https://us06web.zoom.us/webinar/register/WN_f_YXLbaZRRyJsmdYrtDjNQ

ក្រោយចុះឈ្មោះសម្រាប់វគ្គសវនាការពីចម្ងាយហើយ អ្នកនឹងទទួលបានអ៊ីមែលបញ្ជាក់ដែលមានព័ត៌មានអំពីការចូលរួមកិច្ចប្រជុំ។ អ្នកមិនចាំបាច់ត្រូវតែចុះឈ្មោះទុកជាមុនដើម្បីចូលរួមសវនាការណាមួយដោយមានវត្តមានផ្ទាល់នោះឡើយ។ មតិយោបល់ស្ដីពីការកែសម្រួលដែលបានស្នើឡើងអាចនឹងត្រូវបានលើកយកមកបង្ហាញដោយផ្ទាល់មាត់នៅសវនាការសាធារណៈ។

**មតិយោបល់ជាលាយលក្ខណ៍អក្សរនឹងត្រូវបានទទួលយករហូតដល់ម៉ោង 5:00 ល្ងាចនៅថ្ងៃទី 16 ខែធ្នូ ឆ្នាំ 2022**។ មតិយោបល់ដែលបានដាក់ទាំងអស់ត្រូវតែរួមបញ្ចូលនូវឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់បុគ្គលដែលផ្ដល់មតិយោបល់។ សូមដាក់បញ្ជូនមតិយោបល់តាមអ៊ីមែលទៅកាន់អាសយដ្ឋាន **dep.talks@mass.gov** ហើយរួមបញ្ចូល *ចំណងជើងទី 5 និងលិខិតអនុញ្ញាតទីជម្រាល* នៅក្នុងបន្ទាត់ប្រធានបទ។ មតិយោបល់ជាលាយលក្ខណ៍អក្សរក៏អាចនឹងត្រូវបានដាក់បញ្ជូនតាមសំបុត្រផងដែរ ហើយគួរត្រូវផ្ញើទៅកាន់ MassDEP, Bureau of Water Resources – Division of Watershed Management, One Winter Street, 5th floor, Boston, MA 02108, Attention: Title 5 & Watershed Permit។

សម្រាប់ការសម្របសម្រួលពិសេសសម្រាប់សវនាការទាំងនេះ សូមហៅទូរសព្ទទៅកាន់ការិយាល័យភាពចម្រុះរបស់ MassDEP តាមរយៈលេខ 617-348-4040។ TTY# MassRelay Service 1-800-439-2370។ ព័ត៌មាននេះគឺមានជាទ្រង់ទ្រាយផ្សេងទៀតតាមការស្នើសុំ។

MassDEP ផ្ដល់សេវាកម្មអ្នកបកប្រែផ្ទាល់មាត់/បកប្រែអត្ថបទដល់បុគ្គលដែលចេះភាសាអង់គ្លេសតិចតួចដោយឥតគិតថ្លៃ។ ប្រសិនបើអ្នកត្រូវការឲ្យអ្នកបកប្រែផ្ទាល់មាត់ចូលរួមនៅក្នុងកិច្ចប្រជុំនេះ សេវាកម្មបកប្រែភាសាអាចរកបាននៅតាមតំណភ្ជាប់ខាងក្រោម៖ https://www.mass.gov/info-details/massdep-language-translation-assistance។ MassDEP មានបំណងផ្ដល់ជូនសេវាកម្មបកប្រែភាសាអេស្ប៉ាញ និងព័រទុយហ្គាល់នៅសវនាការសាធារណៈ។ សូមផ្ដល់ការជូនដំណឹងជាមុន 72 ម៉ោងប្រសិនបើសេវាកម្មបកប្រែភាសាបន្ថែមទៀតត្រូវបានស្នើសុំ។

តាមបញ្ជារបស់ក្រសួងការពារបរិស្ថាន

Martin Suuberg, ស្នងការ